ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២២៧ សហវ

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងថ្នាក់ដារបើកផ្តល់សំរាប់បើកប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ ក្នុងវិស័យ សង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការនៅអាជ្ញាធរសវនកម្មជាតិ

~ ទេសរដ្ឋមន្ត្រី~រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

~ អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ នឹងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស.រកម/១២៩៩/១៥ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩

-បានឃើញព្រះរាជក្រមលេខ នស.រកម ១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០២

-បានឃើញអនុក្រឹត្យលេខ៨២អ.ន.ក្រ.ប.កចុះថ្ងៃទី ១៦ខែវិច្ឆិកាឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ ១៩៨៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម.ប្រ.ក. ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៨៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន

## សំរេច

**ប្រការ១** :-ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌របស់មន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិ នឹងត្រូវបើកផ្តល់តាមរយៈ " ភ្នាក់ងារបើកផ្តល់ " ។

**ប្រការ២**:-លោក **ដួង កណ្ណារ៉ា** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅអាជ្ញាធរសវនកម្មជាតិនិងលោកស្រី **អៀន សារ៉ុម** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ជំនួស ។

**ប្រការ៣**:-លោក **ដួង កណ្ណារ៉ា** និងលោកស្រី **អៀន សារ៉ុម** ត្រូវបានអនុញ្ញាតឱ្យបើកគណនីប្រាក់បញ្ញើនៅធនាគារជាតិ ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រីរាជការ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌

**ប្រការ៤**:-បែបបទនៃការអនុវត្តន៍បើកផ្តល់ប្រាក់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

**ប្រការ៥**:-ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

**ប្រការ៦**:-អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានធនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**អគ្គសវនករ**
**នៃអាជ្ញាធរសវនកម្មជាតិ**

**អ៊ុត ឈន**

***កន្លែងទទួល*** :

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*" ដើម្បីជូនជ្រាប "*
*-ដូចប្រការ៦*
*"ដើម្បីមុខងារ"*
*-ឯកសារ-កាលប្បវត្តិ*